1

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...១១3៤០.....អពដ

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០១៨

L20180806002 | TD2724

**ជម្រាបជូន**
**លោក-លោកស្រីនាយក**

ឈ្មោះក្រុមហ៊ុន ៖ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (អាយ.ស៊ី.អេស.អូ)
ជាអក្សរឡាតាំង ៖ Indigenous Community Support Organization (I.C.S.O)
លេខអត្តសញ្ញាណកម្ម ៖ 100113591 ចុះបញ្ជីនៅ ៖ សាខាពន្ធដារខណ្ឌចំការមន
អាសយដ្ឋាន ៖ #90 ផ្លូវ 304 សង្កាត់បឹងកេងកងទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ ករណីសំណើសុំលើកលែងពន្ធលើប្រាក់ចំណូល របស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច។
**យោង** ៖ - ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- ប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធ និង អង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ ០៣០/២០១៨/ICSO ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបលោកប្រធានជ្រាបថា អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច បានដាក់លិខិតមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំលើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

អនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងឯកសារពាក់ព័ន្ធរបស់អង្គការ អគ្គនាយកដ្ឋានពន្ធដារ សម្រេចថា អង្គការត្រូវ៖

១- បានលើកលែងពន្ធលើប្រាក់ចំណូលចំពោះចំណូលដែលអង្គការនេះទទួលបានពីមូលនិធិឬអំណោយស្របច្បាប់ពីរូបវន្តបុគ្គលឬនីតិបុគ្គល និងប្រភពដទៃទៀត ដោយអង្គការនេះ បានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅខាងសប្បុរសធម៌។ ក្នុងករណីអង្គការនេះ មានសកម្មភាពស្វែងរកប្រាក់ចំណូលឬសកម្មភាពដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់ខ្លួន ចំណូលឬមូលនិធិដែលទទួលបានត្រូវជាប់ពន្ធលើប្រាក់ចំណូល។ ទន្ទឹមនឹងនេះ អង្គការត្រូវបំពេញកាតព្វកិច្ចសារពើពន្ធដទៃទៀត តាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

២- ធ្វើបច្ចុប្បន្នភាពចុះបញ្ជីពន្ធដារ និងបំពេញកាតព្វកិច្ចពាក់ព័ន្ធជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានអង្គការ ជ្រាប និងអនុវត្តតាមការសម្រេចនេះ។

សូមលោកប្រធានអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ទទួលនូវសេចក្តីរាប់អាន ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន៖**
- សាខាពន្ធដារខណ្ឌចំការមន
"ដើម្បីជូនជ្រាប និងមុខការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh